00648348

E51/4

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អជសដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១១

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ / Public**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សេចក្តីសន្និដ្ឋានអញ្ញត្រកម្មតាមវិធាន ៨៩ របស់លោកអៀង សារី និងការជូនដំណឹងនៃការមិនគោរពតាមតាមអនុស្សារណៈក្រៅផ្លូវការនានានាពេលអនាគត ដែលត្រូវបានចេញជំនួសឲ្យសេចក្តីសម្រេចមានសំអាងហេតុរបស់តុលាការ ដែលជាកម្មវត្ថុបណ្តឹងឧទ្ធរណ៍**

---

| **ដាក់ដោយ៖** | **ផ្ញើជូន៖** | **ផ្ញើជូន៖** |
|---|---|---|
| **សហមេធាវីរបស់លោក អៀង សារី** | **អង្គជំនុំជម្រះសាលាដំបូង** | **សហព្រះរាជអាជ្ញា** |
| លោក អាង ឧត្តម | ចៅក្រម និល ណុន | លោកស្រី ជា លាង |
| លោក Michael G. KARNAVAS | ចៅក្រម ធូ មណី | លោក Andrew CAYLEY |
| | ចៅក្រម យ៉ា សុខន | |
| | ចៅក្រម Silvia CARTWRIGHT | **ក្រុមមេធាវីការពារក្តីទាំងអស់** |
| | ចៅក្រម Jean-Marc LAVERGNE | |
| | ចៅក្រមបំរុង យូរ ឧត្តរ៉ា | |
| | ចៅក្រមបំរុង Claudia FENZ | |

**ឯកសារទទួល**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 25 / 02 / 2011
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

លោក **អៀង សារី** តាមរយៈសហមេធាវីរបស់គាត់ (“មេធាវីការពារក្តី”) អនុលោមតាមអនុស្សារណៈ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១ របស់អ្នកស្រី Susan Lamb មន្ត្រីច្បាប់ជាន់ខ្ពស់នៅអង្គជំនុំជម្រះសាលាដំបូង[1] និងអនុស្សារណៈដែលពាក់ព័ន្ធចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១១[2] តទៅនេះដាក់ “សេចក្តីសង្ខេបនូវរាល់អញ្ញត្រកម្មទាំងអស់របស់គាត់ដោយរួមបញ្ចូលគ្នាក្នុងឯកសារតែមួយ”[3] ។ មេធាវីការពារក្តីស្នើសុំឱ្យពិចារណាថា ការតម្រូវឱ្យដាក់សេចក្តីសង្ខេបនូវរាល់អញ្ញត្រកម្មទាំងអស់របស់គាត់ដោយរួមបញ្ចូលគ្នាក្នុងឯកសារតែមួយ គឺរំលោភលើសិទ្ធិជាមូលដ្ឋានរបស់ អៀង សារី ដែលត្រូវតែបានសវនាការ និងដើម្បីត្រៀមរៀបចំការពារក្តី ។ ការតម្រូវបែបនេះប្រាកដជាមិនបានផ្តល់សម្លេងឱ្យគាត់មានសម្លេងទេ និងបានប្រែក្លាយរូបគាត់គ្រាន់តែជាវត្ថុមិនសំខាន់ក្នុងកិច្ចដំណើរការនីតិវិធីបច្ចុប្បន្ន ជាជាងអ្នកចូលរួមដ៏មានសារៈសំខាន់ម្នាក់។ មេធាវីការពារក្តីព្រួយបារម្ភណ៍ជាខ្លាំងថាការរំលោភសិទ្ធិជាមូលដ្ឋានរបស់លោក អៀង សារី ត្រូវបានបង្កឡើងដោយមន្ត្រីច្បាប់ជាន់ខ្ពស់ ហើយអង្គជំនុំជម្រះសាលាដំបូងក៏មិនបានផ្តល់ការសំអាង-ហេតុជាផ្លូវការទាក់ទងនឹងបញ្ហានេះដែរទេ ។ ហេតុដូច្នេះ មេធាវីការពារក្តីសូមជូនដំណឹងថា ខ្លួននឹងមិនគោរពតាមអនុស្សារណៈក្រៅផ្លូវការនាពេលអនាគត ដែលរំលោភបំពានលើសិទ្ធិជាមូលដ្ឋានរបស់លោក អៀង សារី ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌នោះទេ ។ មេធាវីការពារក្តីស្នើសុំឱ្យពិចារណាថា អង្គជំនុំជម្រះសាលាដំបូង <u>ត្រូវតែ</u>ទទួលយកសារណាបន្ថែមពេញលេញពីមេធាវីការពារក្តីទាក់ទងនឹងអញ្ញត្រកម្មនីមួយៗដូចខាងក្រោម[4]។ អង្គជំនុំជម្រះសាលាដំបូង ប្រហែលជាមិនអាចសម្រេចលើបញ្ហាសំខាន់ជាសារវ័ន្តនានា ដូចជាថាតើ អវតក មានយុត្តាធិការដើម្បីវិនិច្ឆ័យសេចក្តីលោក អៀង សារី ដោយ

---

[1] សូមមើលអនុស្សារណៈរបស់អង្គជំនុំជម្រះសាលាដំបូង៖ នីតិវិធីដែលត្រូវបានកែប្រែរបស់អង្គជំនុំជម្រះសាលាដំបូងសម្រាប់ដាក់អញ្ញត្រកម្ម និងការបញ្ជាក់អំពីកាលកំណត់សម្រាប់ការឆ្លើយតប ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១ (“អនុស្សារណៈថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១”) ។

[2] អនុស្សារណៈរបស់អង្គជំនុំជម្រះសាលាដំបូងៈ អញ្ញត្រកម្ម ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១១ ។

[3] អនុស្សារណៈថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១ នៅទំព័រទី២ ។

[4] ការសង្ខេបពីអញ្ញត្រកម្មនេះត្រូវផ្តល់ឱ្យ យោងទៅលើបដិញ្ញាថាមេធាវីការពារក្តីមិនត្រូវបានផ្តល់នូវការសំអាងហេតុសម្រាប់ការសម្រេចរបស់អង្គបុរេជំនុំជម្រះ បដិសេធអញ្ញត្រកម្មលើបញ្ហាយុត្តាធិការដែលដាក់នៅអង្គបុរេជំនុំជម្រះ ។ សាលដីការបស់អង្គបុរេជំនុំជម្រះត្រូវបានចេញជាមួយការសំអាងហេតុ “នឹងផ្តល់នៅពេលវេលាសមស្រប” ។ *ករណី អៀង សារី* ០០២/១៩/០៩-អវតក/កសចស(អបជ៧៥) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ D427/1/26, ERN: 0063887-00634891 ។ អញ្ញត្រកម្មស្ថាពរអាចផ្លាស់ប្តូរនៅពេលពីមេធាវីការពារក្តីមានឱកាសពិនិត្យការសំអាងហេតុរបស់អង្គបុរេជំនុំជម្រះ ។

00648350



មិនអនុញ្ញាតឱ្យមេធាវីការពារក្តីដាក់អំណះអំណាងពេញលេញបានឡើយ ។

## I សេចក្តីនៃបញ្ហាដែលមេធាវីការពារក្តីប្រឈមនៅក្នុងការលើកឡើងអញ្ញត្រកម្ម

១. អនុលោមតាមវិធាន ៨៩ មេធាវីការពារក្តីមានសិទ្ធិលើកឡើងនូវអញ្ញត្រកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ទាក់ទងនឹងបញ្ហានានាដូចជាយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង ។ វិធានផ្ទៃក្នុងមិនបានដាក់កម្រិតចំនួនអញ្ញត្រកម្មដែលភាគីនីមួយៗអាចលើកឡើងនោះទេ ប៉ុន្តែការណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ អវតក តម្រូវថាអញ្ញត្រកម្មត្រូវមានកម្រាស់ ១៥ ទំព័រ[5]។ បញ្ហានានាដូចជាបញ្ហាយុត្តាធិការតែងតែស្មុគស្មាញ ហើយគេមានការលំបាកក្នុងការលើកអំណះអំណាងចាំបាច់ឱ្យបានគ្រប់គ្រាន់នៅក្នុងសារណាមួយមានកម្រាស់ ១៥ ទំព័រនោះ[6] ។

២. នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១០ កសចស ដាក់ដីកាដំណោះស្រាយនៅក្នុងករណី ០០២[7] ។

៣. នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១០ មេធាវីការពារក្តីដាក់ការជូនដំណឹងនៃការប្តឹងឧទ្ធរណ៍[8] និងក៏បានដាក់សំណើសុំបង្កើនចំនួនទំព័រដើម្បីប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ[9] ។

---

[5] សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ មាត្រា ៥.១ ។

[6] អង្គបុរេជំនុំជម្រះបានទទួលស្គាល់ចំណុចនេះ ។ អង្គបុរេជំនុំជម្រះលើកឡើងថាបញ្ហាយុត្តាធិការដែលបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ដែលដូចគ្នាទៅនឹងបញ្ហាអញ្ញត្រកម្មជាច្រើនដែលលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងដែរ) "លើកឡើងនូវចំណុចជាច្រើន ដែលមិនត្រូវបានគេលើកនៅចំពោះមុខតុលាការកម្ពុជា ហើយនៅក្នុងករណីជាច្រើន ចំណុចទាំងអស់នោះមិនត្រូវបានគេពិចារណានៅក្នុងច្បាប់អន្តរជាតិដែរ ជាពិសេសក្នុងបរិបទរបស់ អវតក .... សិទ្ធិរបស់ភាគីនឹងបានប៉ះពាល់ដោយការខកខានមិនបានវាយតម្លៃ និងដោះស្រាយបានឱ្យគ្រប់គ្រាន់នូវបញ្ហានានាដែលបានលើកឡើង" *ករណី នួន ជា* ០០២/១៩-០៩-២០០៧-អវតក/កសចស អនុស្សរណៈអន្តរការិយាល័យរបស់អង្គបុរេជំនុំជម្រះឆ្លើយតបទៅនឹងអនុស្សរណៈអន្តរការិយាល័យរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១១, ៩ ខែកុម្ភៈ ឆ្នាំ២០១១ D427/1/28, ERN: 00641791-00641796 នៅទំព័រទី២ ។

[7] *ករណី អៀង សារី* ០០២/១៩/០៩-អវតក/កសចស ដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ D427, ERN: 00604508-00605246 ។

[8] *ករណី អៀង សារី* ០០២/១៩/០៩-អវតក/កសចស(អបជ៧៥) សៀវភៅចុះបណ្តឹងឧទ្ធរណ៍របស់មេធាវី អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១១ D427/1។

[9] *ករណី អៀង សារី* ០០២/១៩/០៩-អវតក/កសចស(អបជ៧៥) សំណើជាបន្ទាន់របស់ អៀង សារី សុំបង្កើនមចំនួនទំព័រកំណត់ដើម្បីប្តឹងឧទ្ធរណ៍លើបញ្ហាយុត្តាធិការដែលលើកឡើងនៅក្នុងដីកាដំណោះស្រាយ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១០ D427/1/1។

៤. អង្គបុរេជំនុំជម្រះទទួលយកសំណើនេះនៅថ្ងៃទី១ ខែតុលា ឆ្នាំ២០១០[10] ។ អង្គបុរេជំនុំជម្រះបញ្ជាក់ថា "អង្គបុរេជំនុំជម្រះយល់ឃើញថាភាពស្មុគស្មាញរបស់បញ្ហាចំនួនប្រាំពីរដែលបានលើកឡើង ជាបញ្ហាយុត្តាធិការដែលដើមបណ្តឹងឧទ្ធរណ៍ស្វះស្វែងដើម្បីប្តឹងតវ៉ានេះ បង្កើតបានជាកាលៈទេសៈពិសេសដែលមានចែងនៅក្នុងសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ និងអនុញ្ញាតឱ្យមានការបន្ថែមចំនួនទំព័របាន...។ អង្គបុរេជំនុំជម្រះកត់សម្គាល់បន្ថែមទៀតថាវាជាផលប្រយោជន៍របស់ជនជាប់ចោទក្នុងការទទួលបាននូវដំណោះស្រាយលើបញ្ហាយុត្តាធិការទាំងនេះ ឱ្យបានពេញលេញ និងទូលំទូលាយ តាមដែលអាចធ្វើទៅបាន...[11]។

៥. នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០ មេធាវីការពារក្តីបានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ដែលមានមូលដ្ឋានប្តឹងឧទ្ធរណ៍ចំនួន ១១ មូលដ្ឋាន ដែលមូលដ្ឋាននីមួយៗលើកឡើងពីបញ្ហាយុត្តាធិការរបស់ អវតក[12] ។

៦. នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ អង្គបុរេជំនុំជម្រះបានចេញសេចក្តីសម្រេចរបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ដែលបានរកឃើញថាមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍មួយចំនួនមិនអាចទទួលយកបាន និងបានបដិសេធចោលនូវមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍មួយចំនួន និងបានទទួលយកមួយផ្នែកនៃមូលដ្ឋានមួយចំនួននៃបណ្តឹងឧទ្ធរណ៍ ។ ការសំអាងហេតុលើសេចក្តីសម្រេចនេះ "នឹងផ្តល់នៅពេលវេលាសមស្រប"[13] ។

៧. នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងទទួលបានសំណុំរឿង ។ ចំណុចនេះគឺជាការចាប់ផ្តើមពេលវេលាដាក់អញ្ញត្រកម្ម ដែលពេលវេលាកំណត់គឺត្រឹមថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ

---

[10] *ករណី អៀង សារី* ០០២/១៩/០៩-អវតក/កសចស(អបជ៧៥) សាលដីកាលើសំណើជាបន្ទាន់របស់ អៀង សារី សុំបង្កើនចំនួនទំព័រកំណត់ដើម្បីប្តឹងឧទ្ធរណ៍លើបញ្ហាយុត្តាធិការ ដែលលើកឡើងនៅក្នុងដីកាដំណោះស្រាយ ចុះថ្ងៃទី១ ខែតុលា ឆ្នាំ២០១០ D427/1/3, ERN: 00611380-00611383 នៅកថាខណ្ឌទី ៨-១១។

[11] ដូចខាងលើ កថាខណ្ឌទី១០ដល់១១ ( បញ្ជាក់បន្ថែម) ។

[12] *ករណី អៀង សារី* ០០២/១៩/០៩-អវតក/កសចស(អបជ៧៥) បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០ D427/1/6, ERN: 00617486-00617631 ។

[13] *ករណី អៀង សារី* ០០២/១៩/០៩-អវតក/កសចស(អបជ៧៥) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ D427/1/26, ERN: 00634884-00634891 ។

២០១១[14]។

៨. នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១ មេធាវីការពារក្តីបានដាក់សំណើទៅអង្គជំនុំជម្រះសាលាដំបូងសុំកុំឲ្យចាប់ផ្តើមពេលវេលាកំណត់សម្រាប់បញ្ហាអញ្ញត្រកម្មតាមវិធាន ៨៩ រហូតដល់ពេលដែលអង្គបុរេជំនុំជម្រះផ្តល់សំអាងហេតុទៅលើសាលដីការបស់អង្គបុរេជំនុំជម្រះ លើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ និងសំណើជាបន្ទាន់សុំបន្ថែមពេលវេលា និងបង្កើនចំនួនទំព័រកំណត់ដើម្បីដាក់អញ្ញត្រកម្ម[15]។ ញាតិនេះត្រូវធ្វើឡើងជាចាំបាច់ ពីព្រោះមេធាវីការពារក្តីមិនទាន់ដឹងពីមូលហេតុដែលនាំឲ្យអង្គបុរេជំនុំជម្រះ បដិសេធចោលអញ្ញត្រកម្មផ្នែកយុត្តាធិការ ដែលមេធាវីការពារក្តីបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍របស់ខ្លួន។ អាស្រ័យហេតុនេះ មេធាវីការពារក្តីមិនអាចដឹងថា តើត្រូវទទួលយកការសំអាងហេតុរបស់អង្គបុរេជំនុំជម្រះដែរ ឬអត់ ឬថាតើមានមូលដ្ឋានត្រឹមត្រូវសម្រាប់លើកយកអញ្ញត្រកម្មផ្នែកយុត្តាធិការនេះទៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងដែរ ឬអត់ ។ មេធាវីការពារក្តីនឹងមិនអាចការពារក្តីប្រកបដោយវិរិយភាពបានទេ ប្រសិនបើខ្លួនគ្រាន់តែដាក់អញ្ញត្រកម្មដដែលៗនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដែលអញ្ញត្រទាំងនេះបានដាក់រួចមកហើយនៅចំពោះមុខអង្គបុរេជំនុំជម្រះ ។ ម្យ៉ាងវិញទៀត មេធាវីការពារក្តីពិចារណាថា បញ្ហាយុត្តាធិការដែលនឹងលើកឡើងចំពោះមុខអង្គជំនុំជម្រះសាលាដំបូង គឺជាបញ្ហាស្មុគស្មាញ ហើយបញ្ហានេះនឹងមិនអាចលើកឡើងឲ្យបានគ្រប់គ្រាន់តែក្នុងរយៈពេល ៣០ថ្ងៃ និងនៅក្នុងសារណាកម្រាស់ ១៥ ទំព័របានទេ ។

៩. នៅថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ២០១១ អ្នកនាង Susan Lamb មន្ត្រីច្បាប់ជាន់ខ្ពស់បានផ្ញើអនុស្សរណៈតាមសារអេឡិចត្រូនិចដែលប្រកាសថា "អង្គជំនុំជម្រះសាលាដំបូងនឹងបដិសេធចោលសំណើសុំ

---

[14] *ករណី នួន ជា* ០០២/១៩-០៩-២០០៧-អវតក/កសចស/អជសជ ដីកាបង្គាប់ឲ្យដាក់សម្ភារៈដើម្បីត្រៀមរៀបចំការជំនុំជម្រះ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១ E9, ERN: 00635754-00635759 ។

[15] *ករណី អៀង សារី* ០០២/១៩-០៩-២០០៧/អវតក/អជសជ, សំណើជាបន្ទាន់របស់ អៀង សារី សុំកុំឲ្យចាប់ផ្តើពេលវេលាសម្រាប់បញ្ហាអញ្ញត្រកម្ម រហូតដល់អង្គបុរេជំនុំជម្រះផ្តល់សំអាងហេតុលើសាលាដីការបស់អង្គបុរេជំនុំជម្រះ ទៅលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ និងសំណើជាបន្ទាន់សុំបន្ថែមពេលវេលា និងបង្កើនចំនួនទំព័រកំណត់ដើម្បីដាក់បណ្តឹងអញ្ញត្រកម្ម តាមវិធាន ៨៩ ចុះថ្ងៃទី ២៥ ខែមករា ឆ្នាំ២០១១ E15 ។

ពន្យារថេរវេលាបច្ចុប្បន្នដើម្បីដាក់សម្ភារៈសម្រាប់ការត្រៀមរៀបចំសវនាការ”[16]។ ប៉ុន្តែមានការកត់សម្គាល់ថា “ពុយសនសកម្មអាចកើតចេញពីការខកខានរបស់អង្គបុរេជំនុំជម្រះក្នុងការមិនបានផ្តល់ការសំអាងហេតុទាក់ទងនឹងអញ្ញត្រកម្មទាំងនោះ នៅក្នុងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ”[17]។ អនុស្សរណៈអន្តរការិយាល័យបញ្ជាក់ថា នៅក្នុងពេលវេលាមួយសមស្រប អង្គជំនុំជម្រះសាលាដំបូងនឹងបញ្ជាក់ថា តើសារណាបន្ថែមដែលមានកម្រិតណាខ្លះដែលនឹងតម្រូវឱ្យដាក់ និងទទួលយក នៅពេលការសំអាងហេតុត្រូវបានផ្តល់អោយ ។ អនុស្សរណៈបានបដិសេធចោលសំណើសុំបង្កើនចំនួនទំព័រកំណត់សម្រាប់ដាក់អញ្ញត្រកម្ម និងបានស្នើសុំភាគីឱ្យបង្ហាញអំណះអំណាងនៅក្នុងទម្រង់សង្ខេប។

១០. នៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១១ មេធាវីការពារក្តីបានដាក់សំណើមួយទៅអង្គជំនុំជម្រះសាលាដំបូង ស្នើសុំឱ្យទទួលយកការដាក់អញ្ញត្រកម្មជាភាសាអង់គ្លេស ព្រមជាមួយអត្ថបទបកប្រែជាភាសាខ្មែរនឹងដាក់តាមក្រោយឱ្យបានឆាប់បំផុត តាមដែលអាចធ្វើបាន ដោយសារតែអង្គភាពបកប្រែភាសាជាសំណេរ និងផ្ទាល់មាត់ (ITU) បានជូនដំណឹងមកដល់មេធាវីការពារក្តីថាអង្គភាព ITU មិនអាចបកប្រែអញ្ញត្រកម្មរបស់មេធាវីការពារក្តីឱ្យទាន់កាលកំណត់ដាក់ឯកសារបានឡើយ[18] ។

១១. នៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១១ មន្ត្រីច្បាប់ជាន់ខ្ពស់បានផ្ញើអនុស្សរណៈតាមសារអេឡិចត្រូនិចដែលប្រកាសថា នៅក្នុងករណីដែលភាគីមិនអាចដាក់សំណើជាអត្ថបទបកប្រែជាភាសាខ្មែរតាមកាលកំណត់ដាក់ឯកសារ ភាគីអាចស្នើបញ្ហានោះទៅមន្ត្រីច្បាប់ជាន់ខ្ពស់ ដោយភ្ជាប់ជាមួយឯកសារ

---

[16] *ករណី នួន ជា* ០០២/១៩-០៩-២០០៧-អវតក/កសចស/អជសដ អនុស្សរណៈអន្តរការិយាល័យរបស់ Susan Lamb មន្ត្រីច្បាប់ជាន់ខ្ពស់នៅអង្គជំនុំជម្រះសាលាដំបូង ផ្ញើរជូនភាគីទាំងអស់នៅក្នុងសំណុំរឿង ០០២ ជាជូនដំណឹងជាមុនពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើញាតិ E14, E15, E9/2, E9/3, E/24 and E27, ចុះថ្ងៃទី៣ ខែ កុម្ភៈ ឆ្នាំ២០១១, E35, ERN: 00642291-00642292 (“អនុស្សរណៈអន្តរការិយាល័យចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១១”)។

[17] ដូចខាងលើ ។

[18] *ករណី អៀង សារី* ០០២/១៩-០៩-២០០៧/អវតក/អជសដ, សំណើជាបន្ទាន់របស់ អៀង សារី សុំដាក់អញ្ញត្រកម្មជាភាសាអង់គ្លេស ជាមួយអត្ថបទជាភាសាខ្មែរនឹងដាក់តាមក្រោយ ចុះថ្ងៃទី ៧ ខែកុម្ភៈ ឆ្នា២០១១ E34, ERN: 00642202-00642203 ។

ទំនាក់ទំនងដែលពាក់ព័ន្ធពីអង្គភាព ITU[19] ។ បន្ទាប់មកភាគីអាចផ្តល់ឱ្យមន្ត្រីច្បាប់ជាន់ខ្ពស់ជាមុននូវសំណៅចម្លងនៃឯកសារដែលដាក់ ជាភាសាបារាំង ឬ ភាសាអង់គ្លេស ។ ប្រសិនបើការផ្តល់សំណៅចម្លងនៃឯកសារដែលដាក់នេះត្រូវធ្វើឱ្យបានឆាប់ បន្ទាប់ពីបានដឹងពីការជាប់គាំងនៃការបកប្រែ និងនៅមុនកាលបរិច្ឆេទនៃការដាក់ឯកសារ មន្ត្រីច្បាប់ជាន់ខ្ពស់ថ្លែងថា សំណើនឹងត្រូវពិចារណាថាបានទទួលដោយអង្គជំនុំជម្រះសាលាដំបូងតាមកាលកំណត់ ។ បន្ទាប់មកការដាក់ឯកសារជាផ្លូវការនឹងត្រូវបានអនុញ្ញាត ភ្លាមក្រោយពេលដែលការដាក់ឯកសារមានជាភាសាខ្មែរ និងជាភាសាបារាំង ឬអង់គ្លេស ។

១២. នៅថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១១ មេធាវីការពារក្តីបានបញ្ជូនអញ្ញត្រកម្មចំនួនប្រាំមួយ(៦) ក្នុងចំណោមអញ្ញត្រកម្មទាំងប្រាំបី(៨)របស់ខ្លួន តាមសារអេឡិចត្រូនិច ទៅឱ្យមន្ត្រីច្បាប់ជាន់ខ្ពស់ តាមការស្នើសុំ[20]។ មេធាវីការពារក្តីបានជម្រាបអ្នកស្រីថា អញ្ញត្រកម្មមួយផ្សេងទៀតកំពុងតែត្រូវបានត្រួតពិនិត្យអក្ខរាវិរុទ្ធនិងខ្លឹមសារ (proofread) ហើយអាចបញ្ជូនទៅនៅថ្ងៃបន្ទាប់ ហើយថាអញ្ញត្រកម្មមួយផ្សេងទៀត ត្រូវបានរំពឹងថានឹងបានបកប្រែទាន់ពេលវេលាកំណត់ ហើយដូច្នេះអញ្ញត្រកម្មនេះមិនចាំបាច់បញ្ជូនជាមុនទៅអង្គជំនុំជម្រះសាលាដំបូងឡើយ ។ មេធាវីការពារក្តីក៏បានលើកឡើងនូវបញ្ហានៃក្តីបារម្ភចំនួនពីរ ទាក់ទងនឹងវិធីសាស្ត្របណ្តោះអាសន្នរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការទទួលយកជាមុននូវសំណៅចម្លងនៃសំណើលើកឡើងពីអញ្ញត្រកម្មជាភាសាមួយ៖

ក. ជាទូទៅក្រុមការពារក្តីត្រួតពិនិត្យអក្ខរាវិរុទ្ធនិងខ្លឹមសារ (proofread) និងធ្វើការផ្លាស់ប្តូរតិចតួចចំពោះអត្ថបទភាសាដើមរបស់សំណើ ខណៈដែលសំណើទាំងនេះកំពុងបកប្រែ។ បន្ទាប់មកការផ្លាស់ប្តូរទាំងនេះនឹងបញ្ចូលទៅក្នុងអត្ថបទបកប្រែនៅមុនការដាក់ ។ ជាញឹកញាប់សំណើត្រូវបញ្ជូនទៅបកប្រែ បើទោះបីមេធាវីការពារក្តីកំពុងតែត្រួតពិនិត្យអក្ខរាវិរុទ្ធ និងខ្លឹមសាររបស់វាក៏ដោយ ដោយសារតែពេលវេលាកំណត់សម្រាប់ដាក់ឯកសារមានរយៈពេលខ្លី និងសេចក្តីត្រូវការជាច្រើនថ្ងៃសម្រាប់បកប្រែសំណើនីមួយៗ ។ ជាមួយនីតិវិធីដែលត្រូវកែប្រែ

[19] អនុស្សារណៈផ្ញើពីអង្គជំនុំជម្រះសាលាដំបូង កម្មវត្ថុ៖ នីតិវិធីបណ្តោះអាសន្ននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ក្នុងករណីដែលភាពជាប់គាំងនៃការបកប្រែភាសា ដែលធ្វើឱ្យភាគីមិនអាចដាក់ឯកសារតាមកាលកំណត់បាន ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១១ ("អនុស្សារណៈចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១១") ។

[20] សូមមើលសារអ៊ីម៉ែលរបស់ Tanya Pettay ផ្ញើជូនអ្នកស្រី Lamb, ចុះថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១១ ។

មេធាវីការពារក្តីមិនអាចត្រួតពិនិត្យអត្ថាធិប្បាយ និងខ្លឹមសាររបស់សំណើបានទេ ក្រោយពេលដែលសំណើទាំងនេះត្រូវបានបញ្ជូនទៅបកប្រែ ឬមេធាវីការពារក្តីនឹងដាក់សំណើដែលអាចខុសគ្នាពីសំណៅចម្លងរបស់សំណើដែលមេធាវីការពារក្តីបានបញ្ជូនជាមុន ទៅអង្គជំនុំជម្រះសាលាដំបូង ។

ខ. អនុស្សរណៈចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១១ បញ្ជាក់ថាអង្គជំនុំជម្រះសាលាដំបូងនឹងផ្ញើសំណៅចម្លងនៃសំណើដែលមេធាវីការពារក្តីបញ្ជូនជាមុនមកអង្គជំនុំជម្រះសាលាដំបូង ទៅភាគីដទៃទៀត និងជូនដំណឹងពីពេលវេលាកំណត់សម្រាប់ឲ្យភាគីឆ្លើយតប តាមករណីជាក់ស្តែង ។ មេធាវីការពារក្តីបង្ហាញពីការព្រួយបារម្ភថា ប្រសិនបើភាគីទទួលបានជាមុននូវសំណៅចម្លង ប៉ុន្តែពេលវេលាកំណត់សម្រាប់ភាគីឆ្លើយតប នឹងមិនចាប់ផ្តើមរហូតដល់ការដាក់ជាផ្លូវការនូវសំណើជាពីរភាសានោះទេ ភាគីដទៃទៀតនឹងទទួលបានសារៈប្រយោជន៍ពីការទទួលបាននូវពេលវេលាបន្ថែមដើម្បីរៀបចំការឆ្លើយតប ។

១៣. នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១១ មេធាវីការពារក្តីបានបញ្ជូនអញ្ញត្រកម្មចំនួនពីរ (២) បន្ថែមទៀតតាមសារអេឡិចត្រូនិច ទៅមន្ត្រីច្បាប់ជាន់ខ្ពស់[21] ។

១៤. នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១ អញ្ញត្រកម្មចំនួនពីរ(២) របស់មេធាវីការពារក្តីត្រូវបានដាក់ ដោយសារការបកប្រែអញ្ញត្រកម្មទាំងពីរនេះបានបញ្ចប់រួចរាល់[22] ។ ភាគីត្រូវបានជូនដំណឹងពីអញ្ញត្រកម្មទាំងពីរនេះ នៅថ្ងៃទី១៤ ខែកុម្ភៈ និងនៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ ។

១៥. នៅថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ នៅក្នុងអនុស្សរណៈអន្តរការិយាល័យចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១ ផ្ញើរតាមសារអេឡិចត្រូនិច មន្ត្រីច្បាប់ជាន់ខ្ពស់ស្នើសុំឲ្យមានការកែប្រែនីតិវិធី "សម្រាប់ដាក់អញ្ញត្រកម្មនិងការបញ្ជាក់ពីកាលបរិច្ឆេទសម្រាប់ការឆ្លើយតប"[23]។ មន្ត្រីច្បាប់ជាន់ខ្ពស់ថ្លែងថា

---

[21] សូមមើលសារអ៊ីម៉ែលរបស់អ្នកនាង Tanya Pettay ផ្ញើជូនអ្នកស្រី Lamb, ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១១ ។

[22] សូមមើល*ករណី អៀង សារី* ០០២/១៩-០៩-២០០៧/អវតក/អជសង, អញ្ញត្រកម្មតាមវិធាន ៨៩ របស់ អៀង សារី (អាជ្ញាយុកាលនៃបទល្មើសការរំលោភយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ) ចុះថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ២០១១ E43, ERN: 00643924-00643929 ។ *ករណី អៀង សារី* ០០២/១៩-០៩-២០០៧/អវតក/អជសង, អញ្ញត្រកម្មតាមវិធាន ៨៩ របស់ អៀង សារី (វិធាន ៨៩(១)(គ), ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១ E48, ERN: 00644260-00644265 ។

[23] អនុស្សារណៈចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១ ។

ថ្វីត្បិតតែគាត់ស្នើសុំឲ្យភាគីលើកឡើងអញ្ញត្រកម្ម "នៅក្នុងទម្រង់សង្ខេប" មិនឲ្យលើសពី១៥ ទំព័រជាភាសាអង់គ្លេស ឬ ភាសាបារាំង និង ៣០ ទំព័រជាភាសាខ្មែរ ក៏ភាគីមួយចំនួនបានដាក់ឯកសារជាច្រើន ហើយដែលឯកសារនីមួយៗនោះភាគច្រើនមានចំនួនទំព័រត្រឹមកម្រិតជាអតិបរមា[24]។ មន្ត្រីច្បាប់ជាន់ខ្ពស់ថ្លែងថា អង្គជំនុំជម្រះសាលាដំបូង "ពិនិត្យឃើញថាអញ្ញត្រកម្មមួយចំនួនដែលបានលើកឡើងគឺមានលក្ខណៈដូចគ្នា ឬជាន់គ្នា ។ បន្ថែមពីលើនេះ វាហាក់ដូចជាបង្ហាញថា អញ្ញត្រកម្មមួយចំនួនដែលបានលើកឡើងបង្កើតនូវមន្ទិលសង្ស័យថា តើអញ្ញត្រកម្មដែលបានឡើងជាបញ្ហាទាក់ទងនឹងយុត្តាធិការដែរ ឬអត់ ដូច្នេះហើយអ្វីដែលបានលើកឡើងនោះ នឹងត្រូវពិនិត្យដោយអង្គជំនុំជម្រះថាជាអញ្ញត្រកម្មដែលអាចទទួលយកបានដែរ ឬអត់"[25]។ មន្ត្រីច្បាប់ជាន់ខ្ពស់ថ្លែងថាអង្គជំនុំជម្រះនឹងជូនដំណឹង ដល់ភាគីនៅត្រឹមថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១១ តើឯកសារដែលបានដាក់ខាងលើ ឬផ្នែកមួយចំនួននៃឯកសារទាំងនេះ ត្រូវពិចារណាថាមិនអាចទទួលបានជាអញ្ញត្រកម្ម ។ ដោយរង់ចាំនូវការកំណត់លើឯកសារទាំងនេះ មន្ត្រីច្បាប់ជាន់ខ្ពស់បានថ្លែងថា អង្គជំនុំជម្រះសាលាដំបូង បានបង្គាប់ឲ្យផ្អាកការបកប្រែជាភាសាខ្មែរនូវអញ្ញត្រកម្មទាំងអស់ ដែលបានធ្វើឡើងដោយមិនគោរពតាមការណែនាំពីការកម្រិតចំនួនទំព័រ ។ មន្ត្រីច្បាប់ជាន់ខ្ពស់ណែនាំឲ្យភាគីទាំងអស់ដាក់ "សេចក្តីសង្ខេបនូវរាល់អញ្ញត្រកម្មទាំងអស់របស់ខ្លួនដោយរួមបញ្ចូលគ្នាក្នុងឯកសារតែមួយ មិនឲ្យហួសពីថ្ងៃសុក្រ ទី២៥ ខែកុម្ភៈ ឆ្នាំ២០១១" ។ មន្ត្រីច្បាប់ជាន់ខ្ពស់បានកត់សម្គាល់ថា នាពេលក្រោយទៀត អង្គជំនុំជម្រះសាលាដំបូង អាចស្នើសុំឲ្យភាគីដាក់សារណាលម្អិតបន្ថែមទៀត ទាក់ទងនឹងអញ្ញត្រកម្មដែលបានលើកឡើងនោះ ប្រសិនបើអង្គជំនុំជម្រះជឿជាក់ថា "ចាំបាច់សម្រាប់ការពិចារណាលម្អិតដោយអង្គជំនុំជម្រះ"[26]។

១៦. នៅពីថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១១ មេធាវីការពារក្តីបានបញ្ជូនលិខិតមួយច្បាប់ទៅកាន់ការិយាល័យរដ្ឋបាល និងបានចម្លងជូនអង្គជំនុំជម្រះសាលាដំបូង និងភាគីនានាផងដែរ[27]។ មេធាវីការពារក្តីបានជូនដំណឹងដល់ការិយាល័យរដ្ឋបាលអំពីបញ្ហាដែលខ្លួនបានជួបប្រទះក្នុងការដាក់អញ្ញត្រកម្ម និងអំពី

---

[24] ដូចខាងលើ ។

[25] ដូចខាងលើ ។

[26] ដូចខាងលើ ។

[27] លិខិតផ្ញើរទៅកាន់ការិយាល័យរដ្ឋបាល, កម្មវត្ថុ៖នីតិវិធីដែលបានធ្វើវិសោធនកម្មរបស់អង្គជំនុំជម្រះសាលាដំបូងសម្រាប់ដាក់អញ្ញត្រកម្ម, ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១១។

ចំណាត់ការរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងបញ្ហានេះ ហើយមេធាវីការពារក្ដីបានស្នើសុំឱ្យការិយាល័យរដ្ឋបាល ធ្វើការពិគ្រោះយោបល់ជាមួយអង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងបញ្ហានានាដែលស្ថិតនៅក្រោមអំណាចរបស់ខ្លួន ។ ជាពិសេសមេធាវីការពារក្ដីបានកត់សម្គាល់នូវបញ្ហាដូចខាងក្រោម៖

**ក. អង្គជំនុំជម្រះសាលាដំបូង មិនដែលបានជូនដំណឹងដល់ក្រុមមេធាវីការពារក្ដីថាមានតែអញ្ញត្រកម្មតែមួយប៉ុណ្ណោះក្នុងមួយក្រុមដែលនឹងត្រូវទទួលយក** ។ មេធាវីការពារក្ដីបានស្នើសុំបង្កើនចំនួនទំព័រពី១៥ ទៅដល់ ៤៥ ទំព័រ ដើម្បីដាក់អញ្ញត្រកម្មជាច្រើនទៅអង្គជំនុំជម្រះសាលាដំបូង[28]។ នៅក្នុងសំណើនេះ វាបង្ហាញយ៉ាងច្បាស់ណាស់ថាមេធាវីការពារក្ដីមានបំណងដាក់អញ្ញត្រកម្មជាច្រើន ដែលមិនត្រូវបានហាមឃាត់ដោយវិធានផ្ទៃក្នុងឡើយ។ មន្ត្រីច្បាប់ជាន់ខ្ពស់នៅអង្គជំនុំជម្រះសាលាដំបូងបានបដិសេធចោលនូវសំណើសុំបង្កើនចំនួនទំព័រនេះ តាមសារអេឡិចត្រូនិច[29]។ ចម្លើយតបរបស់មន្ត្រីច្បាប់ជាន់ខ្ពស់តាមរយៈសារអេឡិចត្រូនិក មិនបានធ្វើឱ្យមេធាវីការពារក្ដីជឿជាក់ថាខ្លួនត្រូវបានគេអនុញ្ញាឱ្យដាក់ត្រឹមតែអញ្ញត្រកម្មមួយឡើយ។ មេធាវីការពារក្ដីមិនដែលបានទទួលសេចក្ដីសម្រេចផ្លូវការណាមួយពី អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងសំណើនេះឡើយ។

**ខ. អង្គជំនុំជម្រះសាលាដំបូងហាក់បីដូចជាចាត់ទុកក្រុមមេធាវីការពារក្ដីជាបុគ្គលតែម្នាក់។** អនុស្សារណៈចុះថ្ងៃទី១៤ ខែកុម្ភៈ បានគូសបញ្ជាក់ថា៖ “អញ្ញត្រកម្មជាច្រើនដូចគ្នា ឬជាន់គ្នា”។ បញ្ហាដែលថាអញ្ញត្រកម្មរបស់ក្រុមមេធាវីការពារក្ដីមួយអាចជាន់គ្នាជាមួយអញ្ញត្រកម្មរបស់ក្រុមមេធាវីការពារក្ដីផ្សេងទៀតនោះ គឺមិនពាក់ព័ន្ធនឹងក្រុមមេធាវីការពារក្ដីឡើយ។ ក្រុមមេធាវីការពារក្ដី មិនត្រូវបានគេចាត់ទុកជាបុគ្គលរួមតែម្នាក់ដែលត្រូវគេរំពឹងថានឹងសហការគ្នា និងធានាថាអញ្ញត្រកម្មរបស់ខ្លួនមិនដូចគ្នាទៅនឹងអញ្ញត្រកម្មរបស់ក្រុមមេធាវីការពារក្ដីផ្សេងទៀតនោះឡើយ ។ ក្រុមមេធាវីការពារក្ដីនីមួយៗអាច

---

[28] *ករណីលោក អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/អជសង សំណើបន្ទាន់របស់លោក អៀង សារី សុំមិនឱ្យចាប់ផ្ដើមពេលវេលាដាក់អញ្ញត្រកម្មរហូតទល់តែ អង្គបុរេជំនុំជម្រះផ្ដល់មូលហេតុ ចំពោះសាលដីការបស់ខ្លួនលើបណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនិងដីកាដំណោះស្រាយ និងសំណើបន្ទាន់សុំពន្យារពេលវេលា និងបន្ថែមចំនួនទំព័រក្នុងការដាក់អញ្ញត្រកម្មស្របតាមវិធាន៨៩ នៃវិធានផ្ទៃក្នុង, ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១១, ឯកសារលេខ E15។

[29] អនុស្សារណៈចុះថ្ងៃទី៣ ខែកុម្ភៈ។

មានការប្រកួតប្រជែងខាងផលប្រយោជន៍ដែលអាចកើតឡើងនៅពេលណាមួយ។ មេធាវីការពារក្តីមិនអាចត្រូវបានគេចាត់ទុកជាក្រុមរួមគ្នាតែមួយបានទេ ។ វាមិនមែនជាលើកទីមួយទេដែលមន្ត្រីច្បាប់ជាន់ខ្ពស់រូបនេះ បានធ្វើការអះអាងដែលបង្កជាបញ្ហាបែបនេះ។ នៅក្នុងអនុស្សារណៈចុះថ្ងៃទី៣ ខែកុម្ភៈ មន្ត្រីច្បាប់ជាន់ខ្ពស់ដដែលនេះបានគូសបញ្ជាក់ថាមេធាវីការពារក្តី គួរតែសម្របសម្រួលសំណើរបស់ពួកគេក្នុងករណីដែលអាចធ្វើទៅបានហើយដាក់សំណើរួមគ្នាតែមួយនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[30]។

**គ. ចៅក្រមអង្គជំនុំជម្រះសាលាដំបូងខកខានមិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួន។** យោងតាមអនុស្សារណៈចុះថ្ងៃទី១៤ ខែកុម្ភៈ អង្គជំនុំជម្រះសាលាដំបូងនឹងសម្រេចថាតើអញ្ញត្រកម្មមួយណាអាចទទួលយកបាន សូម្បីតែមុនពេលអញ្ញត្រកម្មទាំងនេះត្រូវបានបកប្រែជាភាសាខ្មែរទៅទៀត ។ អញ្ញត្រកម្មស្ទើរតែទាំងអស់របស់មេធាវីការពារក្តី ត្រូវបានបញ្ជូនតាមសារអេឡិចត្រូនិចទៅកាន់មន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់ជាភាសាអង់គ្លេស រង់ចាំការបកប្រែជាភាសាខ្មែរតាមក្រោយ ។ ការបកប្រែជាភាសាខ្មែរត្រូវបានផ្អាក ហើយមន្ត្រីច្បាប់ជាន់ខ្ពស់បានប្រកាសថាអង្គជំនុំជម្រះសាលាដំបូងនឹងសម្រេចត្រឹមថ្ងៃទី១៨ ខែកុម្ភៈ ២០១១ ថាតើអញ្ញត្រកម្មមួយណាអាចទទួលយកបាន ។ ដោយសារតែអញ្ញត្រកម្មទាំងនេះមិនទាន់ត្រូវបានបកប្រែជាភាសាខ្មែរ ភាពអាចទទួលយកបានទំនងជាត្រូវបានសម្រេចដោយតែអ្នកដែលជាសមាជិកអង្គជំនុំជម្រះសាលាដំបូង ដែលភាសាធ្វើការរបស់អ្នកទាំងនោះជាភាសាអង់គ្លេសតែប៉ុណ្ណោះ ។ ចៅក្រមអង្គជំនុំជម្រះសាលាដំបូងដែលមានភាសាធ្វើការជាភាសាខ្មែរ និងបារាំង អាចមិនបដិសេធក្នុងការបំពេញតួនាទីរបស់ខ្លួន។ អ្នកទាំងនោះត្រូវបានតម្រូវឲ្យពិចារណាអំពីភាពអាចទទួលយកបាន និងខ្លឹមសារនៃអញ្ញត្រកម្ម។

**ឃ. ចំណាត់ការរបស់អង្គជំនុំជម្រះសាលាដំបូងចំពោះបញ្ហានេះ រារាំងមេធាវីការពារក្តីមិនឲ្យធ្វើកំណត់ត្រា។** មន្ត្រីច្បាប់ជាន់ខ្ពស់ បានបដិសេធមិនទទួលយកនូវការដាក់អញ្ញត្រកម្មរបស់មេធាវីការពារក្តីជាផ្លូវការរហូតទល់តែអញ្ញត្រកម្មនោះត្រូវបានបកប្រែជាពីរភាសា។ បន្ទាប់មកអង្គភាពបកប្រែ (ITU) ត្រូវបានបង្គាប់ឲ្យផ្អាកបកប្រែអញ្ញត្រកម្មរបស់យើងខ្ញុំ

---

[30] ដូចជើងទំព័រខាងលើ, ទំព័រទី២។

ទៅជាភាសាខ្មែរ ។ ករណីនេះ មានន័យថាអញ្ញត្រកម្មដែលមេធាវីការពារក្ដីបានតាក់តែង និងដាក់ជូនតាមសារអេឡិចត្រូនិចទៅកាន់អង្គជំនុំជម្រះសាលាដំបូង នឹងមិនអាចត្រូវបានដាក់ជាផ្លូវការ និងមិនត្រូវបានគេដាក់ក្នុងសំណុំរឿងឡើយ។ វានឹងមិនមានកំណត់ត្រាអ្វីឡើយ ដែលថាមេធាវីការពារក្ដីធ្លាប់បានធ្វើអញ្ញត្រកម្មដែលអង្គជំនុំជម្រះសាលាដំបូងចាត់ទុកថាមិនអាចទទួលយកបាននោះឡើយ។

**ឃ. លក្ខណ្ឌតម្រូវឱ្យដាក់អញ្ញត្រកម្មសង្ខេបតែមួយត្រឹម១៥ទំព័រ បានរាំងមេធាវីការពារក្ដីមិនឱ្យបង្ហាញអំណះអំណាងរបស់ខ្លួនឱ្យបានត្រឹមត្រូវ និងរៀបចំការការពារក្ដីដ៏មានប្រសិទ្ធភាព ។** មេធាវីការពារក្ដីមានអញ្ញត្រកម្មជាច្រើនដែលនឹងត្រូវលើកឡើងទាក់ទងនឹងយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង ដែលក្នុងចំណោមនោះរួមមានភាពត្រឹមត្រូវនៃការលើកលែងទោស និងការអភ័យទោសដល់លោក អៀង សារី ថាតើគោលការណ៍មិនជំនុំជម្រះពីរដង បានទប់ស្កាត់ដល់ការកាត់ទោសនៅពេលបច្ចុប្បន្នប្រឆាំងគាត់ដែរឬអត់ និងថាតើ អវតក មានយុត្តាធិការលើឧក្រិដ្ឋកម្មអន្តរជាតិ និងទម្រង់នៃការទទួលខុសត្រូវអន្តរជាតិដែរឬទេ ។ ទាំងនេះ គឺជាបញ្ហាស្មុគស្មាញដែលមានសារៈសំខាន់ចំពោះក្រុមមេធាវីការពារក្ដីលោក អៀង សារី ដោយសារតែពួកគេបានជំទាស់ទៅនឹងគ្រប់បញ្ហាយុត្តាធិការរបស់ អវតក ក្នុងការកាត់ទោសកូនក្ដីរបស់ពួកគេ។ បញ្ហាទាំងនេះមិនអាចត្រូវបានគេយកទៅដោះស្រាយឱ្យបានត្រឹមត្រូវ ក្នុងអញ្ញត្រកម្មសង្ខេបតែមួយដែលមានត្រឹមតែ១៥ទំព័របានឡើយ។ មេធាវីការពារក្ដីមិនអាចការពារក្ដីជូនលោក អៀង សារី ប្រកបដោយវីរិយភាពតាមរយៈការដាក់អញ្ញត្រកម្មសង្ខេបតែមួយ អំពីអំណះអំណាងរបស់ខ្លួនទាំងអស់ ហើយសង្ឃឹមថាអង្គជំនុំជម្រះសាលាដំបូងនឹងស្នើសុំសារណាបំពេញបន្ថែមបានឡើយ។

១៧. កាលពីថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១១ មេធាវីការពារក្ដី បានផ្ញើរលិខិតមួយច្បាប់ទៅកាន់មន្ត្រីច្បាប់ជាន់ខ្ពស់ដែលបញ្ជាក់កម្ពិតអំពីការតវ៉ាខាងលើ[31]។

---

[31] *ករណីលោក អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/អជសដ, លិខិតផ្ញើទៅកាន់លោកស្រី Susan Lamb, កម្មវត្ថុ៖នីតិវិធីដែលបានធ្វើវិសោធនកម្មរបស់អង្គជំនុំជម្រះសាលាដំបូងដើម្បីដាក់អញ្ញត្រកម្ម និងការអះអាងបញ្ជាក់ពីការកំណត់ការបរិច្ឆេទនៃការឆ្លើយតប, ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១១។

១៨. កាលពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១១ មន្ត្រីច្បាប់ជាន់ខ្ពស់ បានផ្ញើអនុស្សារណៈមួយតាមសារអេឡិចត្រូនិចដោយគូសបញ្ជាក់ថា៖ "ក្រុមមេធាវីការពារក្តីលោក អៀង សារី បានបញ្ជូនជាមុននូវសំណៅចម្លងអំពីពាក្យសុំសរុបចំនួន១០១ទំព័រតែជាភាសាអង់គ្លេសមួយប៉ុណ្ណោះ"។ បើពិនិត្យមើលចំនួនទំព័រសរុបនៃពាក្យសុំ [sic] ដែលដាក់ដោយក្រុមមេធាវីការពារក្តីលោក អៀង សារី និងទោះបីជាមានដីកាកាលពីលើកមុនរបស់ខ្លួនក៏ដោយ ឥឡូវនេះ អង្គជំនុំជម្រះសាលាដំបូងតម្រូវឱ្យមេធាវីការពារក្តីដាក់អញ្ញត្រកម្មរួមគ្នាដែលមានចំនួនទំព័រកំណត់ត្រឹម ២៥ទំព័រ ជាភាសាអង់គ្លេស ឬបារាំង និង៥០ទំព័រជាភាសាខ្មែរ[32]"។ មន្ត្រីច្បាប់ជាន់ខ្ពស់ក៏បានគូសបញ្ជាក់ផងដែរថា ខណៈពេលដែលអង្គជំនុំជម្រះសាលាដំបូង "ទទួលស្គាល់ [សំណៅចម្លងដែលបានផ្តល់ជូនជាមុនដោយការយោគយល់នូវអញ្ញត្រកម្មថាជាការបង្ហាញពីការដាក់ឯកសារនៅថ្ងៃអនាគត] ការធ្វើបែបនេះមិនអាចត្រូវបានគេចាត់ទុកថាជាការដាក់ឯកសារផ្លូវការឡើយ ហើយមន្ត្រីច្បាប់ជាន់ខ្ពស់ក៏បានអះអាងទៀតថា "មានតែឯកសាររួមគ្នាតែមួយដែលឆ្លើយតបទៅនឹងកាលបរិច្ឆេទនៃការដាក់ឯកសារដែលបានបញ្ជាក់ដោយអង្គជំនុំជម្រះសាលាដំបូងតែប៉ុណ្ណោះ ទើបជាឯកសារដែលត្រូវបានគេចាត់ទុកថាបានដាក់ជាផ្លូវការ[33]"។

## II. ការជូនដំណឹងពីការមិនអនុវត្តតាមអនុស្សារណៈមិនផ្លូវការនានានៅថ្ងៃអនាគត

១៩. ដូចដែលបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងសវតាខាងលើ មេធាវីការពារក្តីមិនបានទទួលសេចក្តីសម្រេចដែលមានសំអាងហេតុណាមួយពីអង្គជំនុំជម្រះសាលាដំបូង ទាក់ទងនឹងបញ្ហាអញ្ញត្រកម្មឡើយ។ មេធាវីការពារក្តីបានទទួលតែអនុស្សារណៈដែលផ្ញើរតាមសារអេឡិចត្រូនិចដោយមន្ត្រីច្បាប់ជាន់ខ្ពស់តែប៉ុណ្ណោះ[34]។ មេធាវីការពារក្តីគ្មានបំណងបង្អាក់ដំណើរការនីតិវិធី ឬជៀសវាងមិន

---

[32] អនុស្សារណៈ, អង្គជំនុំជម្រះសាលាដំបូង, កម្មវត្ថុ៖ អញ្ញត្រកម្ម, ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១១។

[33] ដូចជើងទំព័រខាងលើ។

[34] មេធាវីការពារក្តីកត់សម្គាល់ឃើញថាអង្គជំនុំជម្រះសាលាដំបូង មានលទ្ធភាពចេញសេចក្តីសម្រេចដែលមានសំអាងហេតុបានយ៉ាងឆាប់រហ័សប្រសិនបើខ្លួនមានបំណងធ្វើដូច្នេះ។ គ្រាន់តែមួយថ្ងៃបន្ទាប់ពីភាគីបានទទួលការជូនដំណឹងថាចៅក្រម និល ណុន នឹងមិនឆ្លើយតបទៅនឹងបណ្តឹងជំទាស់ប្រឆាំងរូបគាត់ អជសជ បានចេញសេចក្តីសម្រេចមួយភ្លាមលើបញ្ហានេះ។ *សូមមើល ករណីលោក អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/អជសជ, សារអេឡិចត្រូនិចរបស់ចៅក្រម និល ណុន ផ្ញើទៅកាន់សមាជិកចៅក្រម អជសជ ទាក់ទងនឹងបណ្តឹងជំទាស់ប្រឆាំងរូបគាត់, ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១១, ឯកសារលេខ

គោរពតាមវិធាន ឬដីកាសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងឡើយ។ មេធាវីការពារក្តីគ្រាន់តែចង់ការពារក្តីលោក អៀង សារី ប្រកបដោយវិរិយភាពតាមរយៈការដាក់អញ្ញត្រកម្មដែលមានសុពលភាពដូចដែលមានចែងក្នុងវិធានផ្ទៃក្នុងតែប៉ុណ្ណោះ។ មេធាវីការពារក្តីទទួលស្គាល់ថាការកកស្ទះក្នុងការបកប្រែភាសា ជួនកាលតម្រូវឱ្យប្រើនីតិវិធីបណ្តោះអាសន្នពិសេសម្តងម្កាលផងដែរ។ ដូច្នេះ ហើយមេធាវីការពារក្តីស្នើសុំការអនុញ្ញាតដាក់អញ្ញត្រកម្មរបស់ខ្លួនជាភាសាអង់គ្លេសជាមុន រួចសឹមដាក់អញ្ញត្រកម្មជាភាសាខ្មែរតាមក្រោយ ។ មេធាវីការពារក្តី ក៏មានបំណងអនុវត្តតាមដំណោះស្រាយរបស់មន្ត្រីច្បាប់ជាន់ខ្ពស់ផងដែរ ក្នុងការបញ្ជូនសំណៅចម្លងអញ្ញត្រកម្មតាមសារអេឡិចត្រូនិចទៅកាន់អង្គជំនុំជម្រះសាលាដំបូង ទោះបីជាខ្លួនបានកត់សម្គាល់ឃើញមានកំហុសឆ្គងមួយចំនួនក្នុងនីតិវិធីនេះក៏ដោយ។

២០. ប៉ុន្តែឥឡូវនេះ តាមរយៈអនុស្សារណៈចុះថ្ងៃទី១៤ និង១៨ មន្ត្រីច្បាប់ជាន់ខ្ពស់ មានបំណងរាំងមេធាវីការពារក្តី មិនឱ្យដាក់ឯកសារអ្វីទាំងអស់ក្រៅតែសេចក្តីសង្ខេបនូវរាល់អញ្ញត្រកម្មទាំងអស់របស់ខ្លួនដោយរួមបញ្ចូលគ្នាក្នុងឯកសារតែមួយ។ លោកស្រីបានយកការកកស្ទះនៃការបកប្រែមកធ្វើជាយុត្តិកម្មទៅលើការរំលោភយ៉ាងច្បាស់ក្រឡែត នូវសិទ្ធិជាមូលដ្ឋានក្នុងការទទួលបានសវនាការ និងការរៀបចំការពារក្តីរបស់លោក អៀង សារី ។ ម្យ៉ាងវិញទៀត សិទ្ធិរបស់លោក អៀង សារី ប្រហែលជាអាចនឹងមិនត្រូវបានគេរំលោភឡើយ ដោយគ្រាន់តែអង្គភាពបកប្រែមិនបានជួលអ្នកបកប្រែអោយបានគ្រប់គ្រាន់នោះទេ។ ជាងនេះទៅទៀត សិទ្ធិរបស់លោក អៀង សារី មិនត្រូវបានគេកំរិតដោយគ្មានសេចក្តីសម្រេចដែលមានសំអាង ហេតុពីអង្គជំនុំជម្រះសាលាដំបូងនោះទេ ដែលមានមូលដ្ឋានចែងក្នុងច្បាប់ជាធរមាននោះឡើយ។

២១. មេធាវីការពារក្តី បានព្យាយាមអនុវត្តតាមអនុស្សារណៈចុងក្រោយបំផុតរបស់មន្ត្រីច្បាប់ជាន់ខ្ពស់ ទោះបីជាអនុស្សារណៈទាំងនេះមិនផ្លូវការ មិនមានសំអាងហេតុ និងច្របូកច្របល់ទាំងនេះ បង្ខំឱ្យភាគីពាក់ព័ន្ធទាំងអស់ធ្វើការថែមម៉ោងយ៉ាងច្រើនរាប់មិនអស់ក៏ដោយ ។ មេធាវីការពារក្តីស្នើសុំ

---

E5/2, ERN: 00640285-00640285, *ករណីលោក អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/អជសដ, សេចក្តីសម្រេច លើបណ្តឹងជំទាស់ចិត្តរបស់លោក អៀង សារី ប្រឆាំងចៅក្រម និល ណុន និងសំណើពាក់ព័ន្ធ, ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១, ឯកសារលេខ E5/3, ERN: 00640427-00640435, ផ្ទុយទៅវិញ មេធាវីការពារក្តីមិនបានទទួលសេចក្តីសម្រេចណាមួយពី អជសដ ទាក់ទងនឹងការដាក់អញ្ញត្រកម្មរបស់ខ្លួនឡើយ។

ការពិចារណាថា បន្ថែមលើការដាក់អញ្ញត្រកម្មក្នុងទម្រង់សង្ខេបនេះ មេធាវីការពារក្ដីត្រូវតែទទួលបានឱកាសដើម្បីបង្ហាញនូវអំណះអំណាងដែលមានសំអាងហេតុពេញលេញ ទៅលើអញ្ញត្រកម្មនីមួយៗរបស់ខ្លួនដូចដែលបានគូសបញ្ជាក់ដូចខាងក្រោម។ ជាងនេះទៅទៀត មេធាវីការពារក្ដីបានផ្ដល់ការកត់សម្គាល់ថា ខ្លួនមិនមានបំណងអនុវត្តតាមអនុស្សារណៈមិនផ្លូវការនានានៅពេលខាងមុខទៀតឡើយ ហើយមេធាវីការពារក្ដីនៅតែស្នើសុំយ៉ាងទទូចថាខ្លួនគួរតែទទួលបានសេចក្ដីសម្រេចដែលមានសំអាងហេតុពីអង្គជំនុំជម្រះសាលាដំបូង។

## III. សេចក្តីសង្ខេបនៃអញ្ញត្រកម្មទាំងឡាយ

២២. អ.វ.ត.ក មិនមានយុត្តាធិការលើលោក អៀង សារី ដោយសារគាត់មានព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះមានសុពលភាព។ ការរៀបរាប់លម្អិតបន្ថែម សូមមើលឯកសារដូចខាងក្រោម៖

ក. *រឿងក្ដី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ០៣), សារណារបស់លោក អៀង សារី អនុលោមតាម *សេចក្ដីសម្រេចអំពីសំណើជាបន្ទាន់របស់ សហមេធាវី សុំពន្យាពេលសមស្រប ក្នុងការដាក់សារណាជំទាស់នឹងបញ្ហាយុត្តាធិការ*, ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០០៨, C22/I/26, ERN: 00184872-00184896។

ខ. *រឿងក្ដី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, ចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអនុលោមតាមវិធាន៦៦ និងសេចក្ដីអង្កេតបន្ថែម, ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១០, D390/1/2/1.3, ERN: 00599372-00599466, កថាខណ្ឌ១៦០-១៦៩។

គ. *រឿងក្ដី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, (អ.ប.ជ ៧៥), បណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០, D427/1/6, ERN: 00621581-00621827, កថាខណ្ឌ៤២-១០២។

ឃ. *រឿងក្ដី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, (អ.ប.ជ ៧៥), សារណាឆ្លើយតបទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី, និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១០, D427/1/23, ERN: 00633297-00633421។

00648363



២៣. អ.វ.ត.ក មិនមានយុត្តាធិការលើលោក អៀង សារី ដោយសារតែ*គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ (ne bis in idem)*។ ការរៀបរាប់លម្អិតបន្ថែម សូមមើលឯកសារដូចខាងក្រោម៖

ក. *រឿងក្តី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ០៣), សារណារបស់លោក អៀង សារី អនុលោមតាម *សេចក្តីសម្រេចអំពីសំណើជាបន្ទាន់របស់ សហមេធាវី សុំពន្យាពេលសមស្រប ក្នុងការដាក់សារណាជំទាស់នឹងបញ្ហាយុត្តាធិការ*, ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០០៨, C22/I/26, ERN: 00184872-00184896។

ខ. *រឿងក្តី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, ចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៦៦ និងសេចក្តីអង្កេតបន្ថែម, ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១០, D390/1/2/1.3, ERN: 00599372-00599466, កថាខណ្ឌ១៤៥-១៥៩។

គ. *រឿងក្តី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, (អ.ប.ជ៧៥), បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០, D427/1/6, ERN: 00621581-00621827, កថាខណ្ឌ២១-៤១។

ឃ. *រឿងក្តី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, (អ.ប.ជ៧៥), សារណាឆ្លើយតបទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី, និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១០, D427/1/23, ERN: 00633297-00633421។

២៤. អ.វ.ត.ក មិនមានយុត្តាធិការអនុវត្តបទល្មើសអន្តរជាតិ និងទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌអន្តរជាតិប្រឆាំងនឹងលោក អៀង សារី នោះទេ។ ការរៀបរាប់លម្អិតបន្ថែម សូមមើលឯកសារដូចខាងក្រោម៖

ក. *រឿងក្ដី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, សំណើរបស់លោក អៀង សារី ប្រឆាំងទៅនឹងលទ្ធភាពនៃការយកច្បាប់ស្ដីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍មកអនុវត្តនៅ អ.វ.ត.ក, ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៩, D240, ERN: 00401941-00401967។

ខ. *រឿងក្ដី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, ពាក្យសុំរបស់លោក អៀង សារី ប្រឆាំងទៅនឹងការអនុវត្តន៍ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅ អ.វ.ត.ក, ចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១០, D378, ERN: 00498553-00498571។

គ. *រឿងក្ដី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, សំណើសុំរបស់ អៀង សារី ជំទាស់ទៅនឹងការអនុវត្តអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ នៅ អ.វ.ត.ក, ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១០, D379, ERN: 00511590-00511610។

ឃ. *រឿងក្ដី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, ពាក្យស្នើសុំរបស់លោក អៀង សារី ប្រឆាំងនឹងការអនុវត្តន៍នៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ដែលគេហៅថា *សហឧក្រិដ្ឋកម្មរួម* (JCE), ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៨, D97, ERN: 00208198-00208224។

ង. *រឿងក្ដី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, (អ.ប.ជ ៧៥), បណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០, D427/1/6, ERN: 00621581-00621827, កថាខណ្ឌ១០៣-១៣៥។

ច. *រឿងក្ដី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, (អ.ប.ជ ៧៥), សារណាឆ្លើយតបទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី, និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១០, D427/1/23, ERN: 00633297-00633421។

២៥. អ.វ.ត.ក មិនមានយុត្តាធិការអនុវត្តការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ប្រឆាំងនឹងលោក អៀង សារី។ ការរៀបរាប់លម្អិតបន្ថែម សូមមើលឯកសារដូចខាងក្រោម៖

ក. *រឿងក្តី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, ចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៦៦ និងសេចក្តីអង្កេតបន្ថែម, ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១០, D390/1/2/1.3, ERN: 00599372-00599466, កថាខណ្ឌ៦៦។

ខ. *រឿងក្តី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, (អ.ប.ជ ៧៥), បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០, D427/1/6, ERN: 00621581-00621827, កថាខណ្ឌ១៣៦-១៣៧។

គ. *រឿងក្តី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, (អ.ប.ជ ៧៥), សារណាឆ្លើយតបទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី, និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១០, D427/1/23, ERN: 00633297-00633421។

ឃ. *រឿងក្តី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ជ, អញ្ញត្រកម្មរបស់ អៀង សារី អនុលោមតាមវិធាន ៨៩ (អាជ្ញាយុកាលលើអំពើបំពារបំពានធ្ងន់ធ្ងរ), ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១, E43, ERN: 00643916-00643923។

២៦. អ.វ.ត.ក មិនមានយុត្តាធិការអនុវត្តការទទួលខុសត្រូវរបស់ថ្នាក់លើ ប្រឆាំងលើរូប លោក អៀង សារី។ ការរៀបរាប់លម្អិតបន្ថែម សូមមើលឯកសារដូចខាងក្រោម៖

ក. *រឿងក្តី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អវតក/កសចស សំណើលោក អៀង សារី ប្រឆាំងនឹងការអនុវត្តការទទួលខុសត្រូវរបស់ថ្នាក់លើនៅ អ.វ.ត.ក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១០ ឯកសារ D345/2 ERN: 00475528-00475551។

ខ. *រឿងក្តី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អវតក/កសចស ជម្រើសមួយនៃសំណើសុំរបស់លោក អៀង សារី ស្តីពីការអនុវត្តការទទួលខុសត្រូវ

របស់ថ្នាក់លើនៅ អ.វ.ត.ក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១០ ឯកសារD345/3 ERN: 00475758-00475774។

គ. *រឿងក្តី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ៦០) បណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីការបស់ ក.ស.ច.ស សម្រេចលើសំណើរបស់លោក អៀង សារី ប្រឆាំងនឹងការអនុវត្តទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ ចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១០ ឯកសារ D345/5/1 ERN: 00497899-00497950។

ឃ. *រឿងក្តី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, ចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអនុលោមតាមវិធាន៦៦ និងសេចក្តីអង្កេតបន្ថែម, ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១០, D390/1/2/1.3, ERN: 00599372-00599466, កថាខណ្ឌ២៥-២៧, ១២៧-១៤៣។

ង. *រឿងក្តី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, (អ.ប.ជ ៧៥), បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០, D427/1/6, ERN: 00621581-00621827, កថាខណ្ឌ២៨៣-៣២៥។

ច. *រឿងក្តី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, (អ.ប.ជ ៧៥), សារណាឆ្លើយតបទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី, និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១០, D427/1/23, ERN: 00633297-00633421។

២៧. អ.វ.ត.ក មានយុត្តាធិការដែលមានកម្រិតក្នុងការអនុវត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ លើរូបលោក អៀង សារី ប្រសិនបើ អ.វ.ត.ក មានយុត្តាធិការក្នុងការអនុវត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ ការរៀបរាប់លម្អិតបន្ថែម សូមមើលឯកសារដូចខាងក្រោម៖

ក. *រឿងក្តី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, ចម្លើយតបរបស់លោក អៀង សារី ទៅនឹងសំណើសុំអោយបំពេញកិច្ចស៊ើបសួររបស់

សហាមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ទាក់ទងបទល្មើសនៃការបាត់ខ្លួនមនុស្សដោយបង្ខំ និង សំណើសុំបន្ថែមចំនួនទំព័រដែលបានកំណត់, ចុះថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០០៩, D180/4, ERN: 00373977-00373994។

ខ. *រឿងក្តី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, សេចក្តីឆ្លើយតបរបស់លោក អៀង សារី ទៅនឹងសំណើរបស់សហាមេធាវីដើមបណ្តឹងរដ្ឋប្បវេណី សុំអោយមានកិច្ចស៊ើបសួរ ស្តីពីអាពាហ៍ពិពាហ៍ដោយបង្ខំ និងទំនាក់ទងផ្លូវភេទដោយបង្ខំ, ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩, D188/3, ERN: 00373661-00373688។

គ. *រឿងក្តី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, ញត្តិផ្សេងទៀតរបស់លោក អៀង សារី ស្តីពីព្រំដែនកម្រិតលទ្ធភាពអនុវត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅ អ.វ.ត.ក, ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១០, D378/2, ERN: 00542133-00542162។

ឃ. *រឿងក្តី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, ចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអនុលោមតាមវិធាន៦៦ និងសេចក្តីអង្កេតបន្ថែម, ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១០, D390/1/2/1.3, ERN: 00599372-00599466, កថាខណ្ឌ២៩-៦៤។

ង. *រឿងក្តី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, (អ.ប.ជ ៧៥), បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០, D427/1/6, ERN: 00621581-00621827, កថាខណ្ឌ១៨៤-២៣១។

២៨. អ.វ.ត.ក មិនមានយុត្តាធិការអនុវត្តបទល្មើសជាតិប្រឆាំងនឹងលោក អៀង សារី នោះទេ។ ការរៀបរាប់លម្អិតបន្ថែម សូមមើលឯកសារដូចខាងក្រោម៖

ក. *រឿងក្តី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អវតក/កសចស ញត្តិរបស់លោក អៀង សារី ប្រឆាំងនឹងការអនុវត្តឧក្រិដ្ឋនានាដែលមានចែងក្នុងមាត្រា៣ថ្មី

00648368



នៃច្បាប់បង្កើត អ.វ.ត.ក (បទល្មើសនៅក្នុងច្បាប់ជាតិ) នៅ អ.វ.ត.ក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០ ឯកសារ D382 ERN: 00532813-00532837។

ខ. *រឿងក្តី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, ចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៦៦ និងសេចក្តីអង្កេតបន្ថែម, ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១០, D390/1/2/1.3, ERN: 00599372-00599466, កថាខណ្ឌ១០៥។

គ. *រឿងក្តី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, (អ.ប.ជ ៧៥), បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០, D427/1/6, ERN: 00621581-00621827, កថាខណ្ឌ១៣៨-១៧៩។

ឃ. *រឿងក្តី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, (អ.ប.ជ ៧៥), សារណាឆ្លើយតបទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី, និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១០, D427/1/23, ERN: 00633297-00633421។

២៩. ការបដិសេធរបស់អង្គជំនុំជម្រះសាលាដំបូងចំពោះការពន្យារថិរវេលា ៣០ថ្ងៃ ក្នុងការដាក់អញ្ញត្រកម្មរហូតក្រោយពេល អង្គបុរេជំនុំជម្រះ ចេញសំអាងហេតុចំពោះសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ត្រូវតែមោឃភាពដោយសារតែមានវិការៈនីតិវិធី។ ការរៀបរាប់លម្អិតបន្ថែម សូមមើលឯកសារដូចខាងក្រោម៖

ក. *រឿងក្តី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ជ, បណ្តឹងអញ្ញត្រកម្ម តាមវិធាន៨៩ របស់ អៀង សារី (វិធាន ៨៩(១)(គ)), ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១, E48, ERN: 00644251-00644259។

## IV. **សំណើសុំ**

**អាស្រ័យហេតុនេះ** ដូចហេតុផលដែលបានជម្រាបជូនខាងលើ មេធាវីការពារក្តីសូមស្នើសុំដោយក្តីគោរព

ដល់អង្គជំនុំជម្រះសាលាដំបូងមេត្តា **សម្រេចថា** អវតក មិនមានយុត្តាធិការទៅលើលោក អៀង សារី ឬជាជម្រើសផ្សេងពីនេះ **សម្រេចថា** យុត្តាធិការត្រូវមានដែនកម្រិត ដូចដែលបានពន្យល់នៅក្នុងការដាក់ឯកសារទាំងឡាយដែលបានយោងនៅទីនេះ។ ម្យ៉ាងវិញទៀត មេធាវីការពារក្តី **ទទូចសុំដល់** អង្គជំនុំជម្រះសាលាដំបូង មេត្តាចេញសេចក្តីសម្រេចដែលមានសំអាងហេតុទៅលើសំណើសុំទាំងឡាយដែលទាក់ទងនឹងបញ្ហានេះ។

សូមចៅក្រមអង្គជំនុំជម្រះសាលាដំបូងទទួលយកការដាក់ឯកសារនេះដោយក្តីគោរព។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **២៥** ខែ កុម្ភៈ ឆ្នាំ ២០១១

ព្រះរាជាណាចក្រកម្ពុជា មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

**អាង ឧត្តម** Michael G. KARNAVAS

សហមេធាវីរបស់លោក **អៀង សារី**